វិទ្យាស្ថានសភាកម្ពុជា
PARLIAMENTARY INSTITUTE OF CAMBODIA

# ឯកសារស្រាវជ្រាវសង្ខេប

## គណៈកម្មការទី៦ នៃព្រឹទ្ធសភា

# ទំនាក់ទំនងរវាងក្រសួងយុត្តិធម៌ និងប្រព័ន្ធតុលាការនៃព្រះរាជាណាចក្រថៃ

ខែសីហា ឆ្នាំ២០១៧

អ្នកស្រាវជ្រាវ៖ កញ្ញា ហេង នីដា
កញ្ញា ជា សុគន្ធមិនា
អ្នកបណ្ដុះបណ្ដាល៖ លោក ឆន ប៉ូល

# កំណត់សម្គាល់

វិទ្យាស្ថានសភាកម្ពុជា(វ.ស.ក)ជាស្ថាប័នឯករាជ្យមួយដែលផ្តល់ការគាំទ្រដល់សភាកម្ពុជាតាមរយៈគឺ ការផ្តល់នូវឯកសារស្រាវជ្រាវទៅតាមសំណើរបស់សមាជិកសមាជិកា និងគណៈកម្មការជំនាញរបស់រដ្ឋសភាព្រឹទ្ធសភា ដែលមានការវិភាគទៅលើបញ្ហាដែលកំពុងតែកើតមាននៅពេលបច្ចុប្បន្ន និងដែលអាចនឹងកើតឡើង នាពេលអនាគតលើប្រធានបទការរៀបចំច្បាប់ និងគោលនយោបាយសាធារណៈ។ ឯកសារទាំងនេះផ្តល់នូវព័ត៌មានផ្សេងៗដែលពាក់ព័ន្ធនឹងការងារសភា និងការងារមណ្ឌល ឬភូមិភាគរបស់សមាជិក-សមាជិការសភា ក៏ប៉ុន្តែរាល់អត្ថន័យដែលមាននៅក្នុងឯកសារទាំងនេះមិនមែនតំណាង ឬឆ្លុះបញ្ចាំងអំពីទស្សនៈផ្ទាល់របស់វិទ្យាស្ថានសភាកម្ពុជា សភា ឬសមាជិក-សមាជិកាណាម្នាក់នោះឡើយ។

ខ្លឹមសារនៃឯកសារទាំងនេះមានកំណត់នូវកាលបរិច្ឆេទរៀបចំច្បាស់លាស់ និងអាចប្រើប្រាស់សម្រាប់តែជាឯកសារយោងប៉ុណ្ណោះ។ ឯកសារទាំងនេះមិនមានគោលបំណងផ្តល់ប្រឹក្សាផ្នែកច្បាប់ ឬទៅលើគោលនយោបាយណាមួយឡើយ ហើយក៏មិនបានធ្វើការសិក្សាអោយបានគ្រប់ប្រធានបទ ឬរាល់ខ្លឹមសារលម្អិតដែល ពាក់ព័ន្ធនឹងបញ្ហាដែលបានលើកឡើងនោះដែរ។

ខ្លឹមសារនៃឯកសារស្រាវជ្រាវសង្ខេបនេះ ស្ថិតក្រោមច្បាប់ជាធរមានរបស់កម្ពុជា និងកិច្ចព្រមព្រៀងអន្តរជាតិស្តីពីសិទ្ធិអ្នកនិពន្ធ។ រាល់ការរៀបចំឡើងវិញដោយដកស្រង់នូវផ្នែកណាមួយ ឬខ្លឹមសារទាំងស្រុងនៃឯកសារស្រាវជ្រាវនេះ ត្រូវមានការអនុញ្ញាតពីវិទ្យាស្ថាន។

រក្សាសិទ្ធិ ឆ្នាំ២០១៧ វិទ្យាស្ថានសភាកម្ពុជា (វ.ស.ក)។

# មាតិកា


១. សេក្តីផ្តើម ........................................................ 1

២ប្រព័ន្ធតុលាការប្រទេសថៃ . ........................................................ 1

៣. គោលការណ៍ជាមូលដ្ឋាននៃឯករាជ្យភាពតុលាការ ........................................................ 3

*ព្រះរាជាណាចក្រថៃ ៖ ឯករាជ្យភាពតុលាការ* ]3, 11, 12] ........................................................ 3

*ក .ឯករាជ្យភាពស្ថាប័ន* ........................................................ 4

*ខ .ឯករាជ្យភាពរបស់ចៅក្រម* ........................................................ 5

៤. ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ........................................................ 6

*៤.១. សន្ធានកម្ម* ........................................................ 7

*៤.២ . មជ្ឈត្តកម្ម* ........................................................ 7

៥. សេចក្តីសន្និដ្ឋាន ........................................................ 8

ឧបសម្ព័ន្ធ ១ ........................................................ 10

ឧបសម្ព័ន្ធ ២ ........................................................ 15

## ១. សេចក្តីផ្តើម

ឯករាជ្យភាពនៃប្រព័ន្ធយុត្តិធម៌មានសារៈសំខាន់សម្រាប់នីតិរដ្ឋ[1]។ ឯករាជ្យភាពរបស់តុលាការមានលក្ខណៈសំខាន់ៗចំនួនពីរគឺ[1] ទីមួយ មិនប្រកាន់បក្សពួក[1] មិនលំអៀងទៅរកភាគីណាមួយជាជាងភាគីមួយផ្សេងទៀត និងផ្តល់ភាពយុត្តិធម៌តាមរយៈការពិត និងភស្តុតាង ទីពីរ ការសម្រេចចិត្តរបស់ចៅក្រម ត្រូវធ្វើដោយគ្មានការគាបសង្កត់ ឬការជ្រៀតជ្រែកពីបុគ្គលដែលនៅក្នុង ឬក្រៅប្រព័ន្ធតុលាការ[1] ។ ទោះជាយ៉ាងណាក៏ដោយក្នុងការអនុវត្ត ការធានាឯករាជ្យភាពតុលាការមិនមានភាពងាយស្រួលទេ ដោយសារមានបញ្ហាប្រឈមជាច្រើន រួមមានការជ្រៀតជ្រែកផ្នែកនយោបាយ ឯករាជ្យភាពថវិកា និងការរងឥទ្ធិពលរវាងចៅក្រមទៅលើគ្នាទៅវិញទៅមក។

ប្រព័ន្ធយុត្តិធម៌នៅប្រទេសថៃ ត្រូវបានធ្វើកំណែទម្រង់ឡើងវិញ ហើយតាមរយៈរដ្ឋធម្មនុញ្ញ មានអំណាចដាច់ដោយឡែកពីរាជរដ្ឋាភិបាល។ គោលបំណងនៃកំណែទម្រង់ប្រព័ន្ធតុលាការ គឺដើម្បីផ្តល់ឲ្យមានឯករាជ្យភាពស្ថាប័នតុលាការ តាមរយៈការលើកកម្ពស់គណនេយ្យភាព ការទទួលបានសេវាយុត្តិធម៌ និងប្រសិទ្ធិភាពរបស់ស្ថាប័នតុលាការ។ លើសពីនេះទៅទៀត កំណែទម្រង់បានដាក់បញ្ចូលយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ (ADR) ដែលជាយន្តការល្អមួយ ដើម្បីដោះស្រាយជម្លោះនៅក្រៅប្រព័ន្ធតុលាការ។

ចាប់តាំងពីឆ្នាំ ២០១៤ មក របបយោធាបានគ្រប់គ្រងរាជរដ្ឋាភិបាល ធ្វើកំណែទម្រង់ និងរៀបចំរដ្ឋធម្មនុញ្ញឡើងវិញ[2]។ យោងតាមមាត្រា២៧៧ និងមាត្រា២៧៩ នៃរដ្ឋធម្មនុញ្ញបណ្តោះអាសន្នឆ្នាំ២០១៦ ប្រព័ន្ធតុលាការ ត្រូវបានចាត់ទុកថាមានធម្មនុញ្ញភាព មានភាពស្របច្បាប់ នឹងបន្តមានអនុភាពក្រោមរដ្ឋធម្មនុញ្ញឆ្នាំ ២០១៦[3] ។ ដោយផ្អែកតាមឯកសារដែលមានស្រាប់ ឯកសារសង្ខេបនេះ នឹងឆ្លើយសំណួរស្រាវជ្រាវចំនួនពីរដូចខាងក្រោម:

១. តើប្រព័ន្ធតុលាការប្រទេសថៃមានឯករាជ្យភាពយ៉ាងដូចម្តេចពីក្រសួងយុត្តិធម៌?
២. តើប្រទេសថៃអនុវត្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការយ៉ាងដូចម្តេច?

## ២. ប្រព័ន្ធតុលាការប្រទេសថៃ

ប្រទេសថៃប្រកាន់យកប្រព័ន្ធច្បាប់ស៊ីវិល។ នៅក្នុងបរិបទប្រទេសថៃ ក្រមច្បាប់បានយកលំនាំតាមគំរូរបស់ប្រទេសបារាំង អាឡឺម៉ង់ និងជប៉ុន ព្រមទាំងទទួលឥទ្ធិពលពីប្រពៃណី និងទំនៀមទំលាប់របស់ប្រទេសថៃ[4]។ លើសពីនេះទៀត មាតិកាភាគច្រើននៃច្បាប់ ត្រូវបានយកចេញពីច្បាប់នៃបណ្តាប្រទេសដទៃទៀត ហើយក៏ទទួលឥទ្ធិពល ច្បាប់នៃប្រទេសដែលប្រកាន់យកប្រព័ន្ធច្បាប់ខមិនឡន៍ (common law) ដូចជាចក្រភពអង់គ្លេសជាដើម[4]។

ប្រព័ន្ធយុត្តិធម៌របស់ប្រទេសថៃ បែងចែកតុលាការជាបីថ្នាក់ (រូបភាពទី១ ខាងក្រោម) ដែលត្រូវបានគេស្គាល់ជាទូទៅថាជាតុលាការយុត្តិធម៌[5] ។ តុលាការកំពូល គឺជាតុលាការជាន់ខ្ពស់ បន្ទាប់មក សាលាឧទ្ធរណ៍ និង

តុលាការសាលាដំបូងដែលជាតុលាការជាន់ទាប[3] ។ ក្រៅពីតុលាការយុត្តិធម៌ នៅមានតុលាការបីប្រភេទផ្សេងគ្នា គឺតុលាការរដ្ឋបាល[6] តុលាការធម្មនុញ្ញ[7] និងតុលាការយោធា។ លើសពីនេះទៅទៀតក៏មានតុលាការឯកទេសជាច្រើនទៀតដែលដោះស្រាយបញ្ហាជាក់លាក់មួយចំនួន ដូចជាតុលាការការងារកណ្តាល តុលាការពន្ធដារកណ្តាល តុលាការកម្មសិទ្ធិបញ្ញាកណ្តាល តុលាការពាណិជ្ជកម្មអន្តរជាតិ និងតុលាការក្ស័យធន (មើលរូបភាពទី១ ខាងក្រោម)[5] ។ សាលាឧទ្ធរណ៍រួមមាន សាលាឧទ្ធរណ៍ និងសាលាឧទ្ធរណ៍តំបន់មានចំនួនប្រាំបួន[5] ដែលមានទីតាំងខុសៗគ្នាទៅតាមតំបន់នីមួយៗ។

**តារាងទី១៖ រចនាសម្ព័ន្ធតុលាការយុត្តិធម៌[8]**



## ៣. គោលការណ៍ជាមូលដ្ឋាននៃឯករាជ្យភាពតុលាការ

ចាប់តាំងពីប្រព័ន្ធយុត្តិធម៌ជាផ្នែកមួយក្នុងការផ្តល់យុត្តិធម៌ និងការពារសិទ្ធិមនុស្ស ឯករាជ្យភាពតុលាការពិតជាមានសារៈសំខាន់ណាស់។ ក្នុងឆ្នាំ១៩៨៥ មហាសន្និបាតអង្គការសហប្រជាជាតិ បានបង្កើតគោលការណ៍ជាមូលដ្ឋានគ្រឹះ ស្តីពី ឯករាជ្យភាពរបស់តុលាការ[9]។ គោលការណ៍នេះអាចត្រូវបានប្រើជាគំរូសម្រាប់ប្រទេសនីមួយៗ ដើម្បីអនុម័តនៅក្នុងរដ្ឋធម្មនុញ្ញ[9] ។ បើទោះជាយ៉ាងណាក៏ដោយ នៅក្នុងស្ថានភាពជាក់ស្តែង គោលការណ៍នេះ មិនត្រូវបានអនុវត្តពេញលេញនៅឡើយទេ[10]។ ដើម្បីវាស់វែងឯករាជ្យភាពប្រព័ន្ធយុត្តិធម៌ លក្ខណៈវិនិច្ឆ័យមួយចំនួនត្រូវបានបង្កើតឡើង ដែលអាចសង្ខេបជាបួនផ្នែកដូចខាងក្រោម៖

- **ល័ក្ខខ័ណ្ឌដែលត្រូវបានធានា៖** ជាទូទៅរដ្ឋធម្មនុញ្ញនៃប្រទេសនីមួយៗបានចែងថា ការបែងចែកអំណាចទាំងបីគឺអំណាចនីតិប្រតិបត្តិ អំណាចនីតិប្បញ្ញត្តិ និងអំណាចតុលាការ។ ដូច្នេះអំណាចនីមួយៗ ជាពិសេសអំណាចតុលាការត្រូវបានធានាឲ្យមានឯករាជ្យដោយរដ្ឋធម្មនុញ្ញ។ ដើម្បីធានាថាតួនាទី និងភារកិច្ចតុលាការមិនស្ថិតនៅក្រោមឥទ្ធិពលរបស់អំណាចខាងក្រៅផ្សេងទៀយ។

- **ការសម្រេចចិត្ត និងសិទ្ធិអំណាច៖** ប្រព័ន្ធតុលាការមានអំណាច និងសិទ្ធិដើម្បីធ្វើការសម្រេចចិត្តដោយឯករាជ្យ។ ការសម្រេចចិត្តចុងក្រោយមិនត្រូវផ្លាស់ប្តូរដោយអំណាចខាងក្រៅផ្សេងទៀយ។

- **ឯករាជ្យភាពថវិកា៖** នេះគឺជាកត្តាសំខាន់ដែលធានាថាប្រព័ន្ធតុលាការ មានធនធានថវិកាគ្រប់គ្រាន់ ដើម្បីបំពេញតួនាទី និងភារកិច្ចឱ្យមានប្រសិទ្ធភាព។ ប្រសិនបើអង្គតុលាការមិនមានស្វ័យភាពលើថវិការបស់ខ្លួនទេនោះ អំណាចដទៃទៀតអាចនឹងជ្រៀតជ្រែក ដល់ការធ្វើសេចក្តីសម្រេចចិត្តរបស់តុលាការ។

-**គុណសម្បត្តិរបស់ចៅក្រម៖** ការជ្រើសរើសចៅក្រមអាស្រ័យលើសមត្ថភាព និងគុណសម្បត្តិរបស់ចៅក្រម។ ប្រសិនបើរាជរដ្ឋាភិបាល គឺជាអ្នកដែលតែងតាំងចៅក្រម រដ្ឋធម្មនុញ្ញ ឬច្បាប់ជាក់លាក់ណាមួយគួរតែធានាឱ្យមានតម្លាភាព និងកំណត់លក្ខណៈវិនិច្ឆ័យច្បាស់លាស់សម្រាប់ការតែងតាំង។ ដើម្បីធានាថា ចៅក្រមមានសមត្ថភាពអនុវត្តតួនាទី ភារកិច្ច និងធ្វើការសម្រេចចិត្តប្រកបដោយប្រសិទ្ធភាព។

### *ព្រះរាជាណាចក្រថៃ ៖ ឯករាជ្យភាពតុលាការ* [3, 11, 12]

ប្រទេសថៃ ធ្លាប់ជាប្រទេសប្រជាធិបតេយ្យដែលគោរពគោលការណ៍នៃការបែងចែកអំណាច[3]។ ទោះបីជាយ៉ាងណាក៏ដោយ ចាប់តាំងពីរបបយោធាបានគ្រប់គ្រងប្រទេសថៃនៅក្នុងខែឧសភាឆ្នាំ២០១៤ អំណាចតុលាការត្រូវបានកាត់បន្ថយ។ ទោះជាយ៉ាងនេះក៏ដោយ គោលគំនិតនៃការបែងចែកអំណាច គឺមានសារៈសំខាន់ណាស់សម្រាប់ឯករាជ្យភាពតុលាការ ដើម្បីរក្សាបាននូវ "ប្រព័ន្ធត្រួតពិនិត្យ និងតុល្យភាពអំណាច" រវាងអំណាចទាំងបី [13] ។ ពិតជាមានសារៈសំខាន់ណាស់ ដែលថាការសម្រេចចិត្តរបស់ចៅក្រម មិនត្រូវបានជ្រៀតជ្រែកដោយបុគ្គល ឬស្ថាប័នណាមួយឡើយ និងមិនមានការគាបសង្កត់ណាមួយទៅលើតុលាការដោយរាជរដ្ឋាភិបាល ឬសភា។ គោលការណ៍ជាមូលដ្ឋានគ្រឹះ ស្តីពី ឯករាជ្យភាពរបស់តុលាការ[14] ត្រូវបានអនុវត្ត ដើម្បីពិនិត្យមើលឯករាជ្យភាពតុលាការនៅក្នុងប្រទេសថៃផងដែរ។

ផ្នែកខាងក្រោមនេះបង្ហាញពី ឯករាជ្យភាពរបស់តុលាការយុត្តិធម៌ថៃ។ គោលការណ៍ឯករាជ្យភាពនៃតុលាការអាចបែងចែកជាពីរប្រភេទគឺ ៖ ឯករាជ្យភាពស្ថាប័ន និងឯករាជ្យភាពរបស់ចៅក្រម[14]។

## ក.ឯករាជ្យភាពស្ថាប័ន

ឯករាជ្យភាពស្ថាប័ន ឆ្លុះបញ្ចាំងពីគោលការណ៍នៃការបែងចែកអំណាច ដូចដែលបានចែងនៅក្នុងរដ្ឋធម្មនុញ្ញ។ ដោយមើលឃើញពីសារៈសំខាន់នៃឯករាជ្យភាពរបស់ប្រព័ន្ធតុលាការ មន្ត្រីរដ្ឋបាល (administrative personnel) និងថវិការបស់ប្រព័ន្ធតុលាការ ត្រូវតែមានឯករាជ្យភាព ដើម្បីកាត់បន្ថយនូវការគ្រប់គ្រងពីសំណាក់ស្ថាប័ននីតិបញ្ញត្តិ និងនីតិប្រតិបត្តិ ទៅលើប្រតិបត្តិការរបស់តុលាការ និងរដ្ឋបាលរបស់តុលាការ[15]។ ប្រព័ន្ធតុលាការ គួរតែមានឯករាជ្យភាព និងមិនទទួលឥទ្ធិពលពីភាគីខាងក្រៅ រួមទាំងអំណាចប្រតិបត្តិ និងអំណាចនីតិប្បញ្ញត្តិ។

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រថៃ បានបែងចែកអំណាចជាបីគឺ៖ អំណាចនីតិប្រតិបត្តិ អំណាចនីតិបញ្ញត្តិ និងអំណាចតុលាការ[3]។ នៅក្នុងឆ្នាំ១៨៩២ ក្រសួងយុត្តិធម៌ ត្រូវបានបង្កើតឡើង ដោយតុលាការទាំងអស់ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងយុត្តិធម៌[2]។ ក្រសួងយុត្តិធម៌ ត្រូវបានធ្វើកំណែទម្រង់នៅក្នុងឆ្នាំ១៩៩១ ខណៈពេលដែលភ្នាក់ងាររាជរដ្ឋាភិបាល[a] មួយចំនួន ស្ថិតនៅក្រោមក្រសួងយុត្តិធម៌ ដោយឡែកតុលាការទាំងអស់ មានឯករាជ្យភាពពីក្រសួងយុត្តិធម៌ លើកលែងតែតុលាការយោធា[3]។ លើសពីនេះទៅទៀត មាត្រា១៩៣ នៃរដ្ឋធម្មនុញ្ញឆ្នាំ២០១៦ បានចែងថា ប្រព័ន្ធតុលាការ មានឯករាជ្យភាពផ្នែករដ្ឋបាលពីក្រសួងយុត្តិធម៌ រួមមានមន្ត្រីរដ្ឋបាល (administrative personnel) និងថវិកា លើកលែងតែតុលាការយោធា[3]។ យោងតាមមាត្រា៣២ នៃច្បាប់ស្តីពីរដ្ឋបាលតុលាការនៃតុលាការយុត្តិធម៌ (Act of Judicial Administration of the Courts of Justice) បានចែងថា "ការិយាល័យនៃប្រព័ន្ធយុត្តិធម៌ (Office of the Judiciary) ត្រូវស្នើថវិកាចំណាយទៅគណៈរដ្ឋមន្ត្រី ដើម្បីបែងចែកថវិកាទៅតុលាការយុត្តិធម៌ និងការិយាល័យតុលាការ (Office of Judiciary)[12]"។ គោលបំណងនៃការផ្តាច់ប្រព័ន្ធតុលាការពីក្រសួងយុត្តិធម៌ គឺដើម្បីធានាដំណើរការតុលាការប្រកបដោយប្រសិទ្ធភាព គណនេយ្យភាព តម្លាភាព និងឯករាជ្យភាព។

យោងតាមមាត្រា១៤ និងមាត្រា២៦ នៃច្បាប់ស្តីពីសេវាយុត្តិធម៌ (Act of Judicial Service) នៅក្នុងតុលាការយុត្តិធម៌ ចៅក្រមដែលជាសិក្ខាកាម ត្រូវឆ្លងកាត់ការប្រឡង ដែលរៀបចំឡើងដោយគណៈកម្មការតុលាការ (Judicial Commission) មុនពេលត្រូវបានតែងតាំងដោយប្រធានតុលាការកំពូល[11]។ ដូច្នេះចៅក្រមនៅក្នុងតុលាការយុត្តិធម៌ ត្រូវទទួលការតែងតាំងដោយគណៈកម្មការតុលាការ (Judicial Commission)[11]។ យោងតាមច្បាប់ដដែលនេះ មិនមានបុគ្គលណាម្នាក់នៅក្នុងស្ថាប័ននីតិប្រតិបត្តិ ឬនីតិ-

---

[a] ភ្នាក់ងារដែលស្ថិតនៅក្រោមក្រសួងយុត្តិធម៌រួមមាន៖ នាយកដ្ឋានស៊ើបអង្កេតពិសេស នាយកដ្ឋានស៊ើបអង្កេតនិងការពារអនីតិជន ការិយាល័យកិច្ចការយុត្តិធម៌ ការិយាល័យអគ្គលេខាធិការដ្ឋាន នាយកដ្ឋានការអនុវត្តច្បាប់ នាយកដ្ឋានស៊ើបអង្កេតពិសេស មជ្ឈមណ្ឌលវិទ្យាសាស្ត្រកោសល្យវិច្ច័យ(CIFS) នាយកដ្ឋានការពារសិទ្ធិនិងសេរីភាព និងការិយាល័យក្រសួង។

បញ្ញត្តិ ចូលរួមដោយផ្ទាល់នៅក្នុងការតែងតាំងចៅក្រមឡើយ។ ជាលទ្ធផល ដំណើរការនៃការតែងតាំងនៅក្នុងប្រព័ន្ធតុលាការ គឺឯករាជ្យពីអំណាចនយោបាយ ឯចៅក្រមទាំងអស់ អាចមានទំនុកចិត្តក្នុងការបំពេញមុខងាររបស់ខ្លួន។

គណកម្មការតុលាការ (Judicial Commission) ជានានូវការការពារចៅក្រម ដែលបំពេញមុខងារ និងភារកិច្ចរបស់ខ្លួន។ លើសពីនេះទៅទៀត រដ្ឋធម្មនុញ្ញ បានចែងថា ការផ្ទេរចៅក្រម ដោយគ្មានការព្រមព្រៀងជាមុន មិនត្រូវបានអនុញ្ញាតិឡើយ លើកលែងតែក្នុងករណីដែលការផ្ទេរត្រូវបានចែងដោយច្បាប់ រួមមានការដំឡើងឋានៈ ការដាក់ទណ្ឌកម្មវិន័យ ឬការចោទប្រកាន់ពីការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ[11]។ ការដាក់ទណ្ឌកម្មវិន័យ មាន៥ប្រភេទ ដូចជាការបណ្តេញចេញពីការងារ ការដកហូតដំណែង ការរំលត់កាតព្វកិច្ច ការពន្យាពេលឡើងដំណែង ឬតម្លើងប្រាក់បៀវត្ស និងការស្តីបន្ទោស[11]។

## ខ. ឯករាជ្យភាពរបស់ចៅក្រម

ការកត់សម្គាល់ រវាងភាពខុសគ្នានៃឯករាជ្យភាពរបស់ចៅក្រមក្នុងការធ្វើសេចក្តីសម្រេចចិត្ត និងឯករាជ្យភាពរបស់ប្រព័ន្ធតុលាការពីអំណាចដទៃទៀត មានសារៈសំខាន់ណាស់[15]។ នៅប្រទេសថៃ ច្បាប់ធានានូវឯករាជ្យភាពរបស់ស្ថាប័ន ប៉ុន្តែច្បាប់ មិនបានធានានូវឯករាជ្យភាពរបស់ចៅក្រមក្នុងការធ្វើសេចក្តីសម្រេចចិត្តឡើយ[15]។ ជាទូទៅ ចៅក្រមជាន់ខ្ពស់នៃតុលាការយុត្តិធម៌ មានឥទ្ធិពលទៅលើចៅក្រមជាន់ទាប ជាពិសេសពាក់ព័ន្ធការធ្វើសេចក្តីសម្រេចចិត្ត។ ដូច្នេះ ចៅក្រមជាន់ទាប អាចមានសម្ពាធពីចៅក្រមជាន់ខ្ពស់ពាក់ព័ន្ធនឹងការសម្រេចចិត្ត[15]។ ចៅក្រមជាន់ទាប ដែលងាយនឹងទទួលឥទ្ធិពលនេះ រំពឹងថានឹងត្រូវបានតម្លើងឋានៈ និងផ្តល់ការវាយតម្លៃទៅលើគុណសម្បត្តិ]15]។ កត្តានេះ អាចជះឥទ្ធិពលទៅលើ ឯករាជ្យភាពនៃការសម្រេចចិត្ត។ ទោះជាយ៉ាងណាក៏ដោយ ចៅក្រមនៃតុលាការយុត្តិធម៌ ត្រូវបានតែងតាំងដោយគណៈកម្មការតុលាការ (Judicial Commission) តាមរយៈដំណើរការនៃការប្រលង[11]។

ដើម្បីធានាឯករាជ្យភាពតុលាការ គណៈកម្មការតុលាការ (Judicial Commission) ត្រូវបានបង្កើតឡើងដើម្បីត្រួតពិនិត្យទៅលើការតែងតាំង ការតម្លើងឋានៈ និងការដាក់វិន័យចៅក្រម[11]។ គណៈកម្មការតុលាការ (Judicial Commission) ដឹកនាំដោយប្រធានតុលាការកំពូល និងមានចៅក្រមចំនួន១២រូប ដែលតំណាងឲ្យតុលាការគ្រប់កម្រិត (ចៅក្រម៤រូបមកពីតុលាការកំពូល ចៅក្រម៤រូបមកពីសាលាឧទ្ធរណ៍ និង៤រូបទៀតមកពីសាលាដំបូង) និងសមាជិកគណៈកម្មការ ២រូប មកពីព្រឹទ្ធសភា។ គណៈកម្មការនេះ ត្រូវបានបង្កើតឡើង ដើម្បីធានាឯករាជ្យភាពរបស់ចៅក្រម[11]។

តារាងទី២៖ ឯករាជ្យភាពតុលាការ[16]




តារាងទី២ នេះបង្ហាញពីឯករាជ្យភាពរបស់តុលាការនៅប្រទេសថៃ ពីសមាជិករដ្ឋាភិបាល អង្គការ ឬប្រជាជន ពីឆ្នាំ២០០៧ ដល់ ២០១៦ (ពិន្ទុ១៖ ឥទ្ធិពលខ្លាំង និងពិន្ទុ៧៖ ឯករាជ្យទាំងស្រុង) ។ ក្នុងអំឡុងមួយទសវត្សរ៍ ពិន្ទុនៃឯករាជ្យភាពតុលាការនៅប្រទេសថៃមានការថយចុះជាលំដាប់ពី ៤.៧២ នៅក្នុងឆ្នាំ២០០៧ មកត្រឹម៤.០២នៅឆ្នាំ២០១៦ ។ នៅដើមឆ្នាំ២០១៤ របបយោធាបានគ្រប់គ្រងប្រទេសថៃទាំងមូល យ៉ាងណាមិញ ពិន្ទុនៃឯករាជ្យភាពតុលាការបានធ្លាក់ចុះមកត្រឹមតែ៣.៨០ ។ បើទោះជាយ៉ាងណាក៏ដោយ នៅឆ្នាំ២០១៦ ពិន្ទុនៃឯករាជ្យភាពតុលាការមានការកើនឡើងបន្តិចម្តងៗមកត្រឹម ៤.០២ ។

## ៤. ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ

បណ្តឹងវិវាទ (Litigation) គឺជាវិធីដោះស្រាយវិវាទទាំងនៅក្នុងវិស័យសាធារណៈ និងវិស័យឯកជន។ ដោយសារតែវិវាទនៅក្នុងប្រទេសថៃ មានការកើនឡើង ហើយប្រព័ន្ធតុលាការ មានការលំបាកក្នុងការដោះស្រាយវិវាទទាំងអស់ប្រកបដោយប្រសិទ្ធភាព ដែលក្នុងករណីខ្លះ នាំឲ្យមានការចំណាយរយៈពេលយូរ ដើម្បីបញ្ចប់រឿងក្តី[17]។

ឆ្លើយតបទៅនឹងបញ្ហានេះ ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ (ADR) ត្រូវបានអនុវត្តនៅក្នុងប្រទេសថៃតាំងពី២០ឆ្នាំមុន [18]។ ADRs ដើរតួយ៉ាងសំខាន់នៅក្នុងប្រព័ន្ធច្បាប់របស់ប្រទេសថៃ។ រាជរដ្ឋាភិបាលថៃបានជម្រុញប្រជាពលរដ្ឋថៃឲ្យប្រើប្រាស់ដំណោះស្រាយប្រភេទនេះ មុនពេលដែលរឿងក្តីឡើងដល់តុលាការ ដើម្បីឲ្យភាគីវិវាទ អាចសន្សំសំចៃពេលវេលា និងការចំណាយ។ ដើម្បីជានានូវការអនុវត្ត ADRនេះ ការិយាល័យដោះស្រាយវិវាទក្រៅប្រព័ន្ធ (Alternative Dispute Resolution Office) ត្រូវបានបង្កើតឡើងដោយការិយាល័យនេះ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ការិយាល័យតុលាការ (Office of the Judiciary)[17]។

ADR មាន ២ប្រភេទ គឺសន្ទានកម្ម និង មជ្ឈត្តកម្ម។ សន្ទានកម្ម និង មជ្ឈត្តកម្ម រួមមានទាំងនីតិវិធីនៅក្នុងតុលាការ និងក្រៅតុលាការ[19]។

### ៤.១. សន្ទានកម្ម

សន្ទានកម្ម ត្រូវបានប្រើប្រាស់ជាយូរមកហើយនៅក្នុងប្រទេសថៃ ប៉ុន្តែត្រូវបានគេប្រើប្រាស់ជាញឹកញាប់នៅក្នុងវិវាទតូចៗ។ ក្រមនីតិវិធីរដ្ឋប្បវេណី ដែលត្រូវបានអនុម័តជាលើកដំបូងនៅក្នុងឆ្នាំ១៩៣៥ បានចែងថា សន្ទានកម្ម អាចធ្វើឡើងដែលតម្រូវដោយចៅក្រមជំនុំជម្រះ ឬអាចធ្វើឡើងតាមរយៈកិច្ចព្រមព្រៀងរវាងភាគីវិវាទទាំងពីរ[19]។ ដើម្បីកាត់បន្ថយការចំណាយរបស់ភាគីទាំងពីរ ការិយាល័យតុលាការ (Office of the Judiciary) ឧបត្ថម្ភថវិកាដល់ដំណើរការនៃសន្ទានកម្មនេះ[17]។

ចំពោះសន្ទានកម្មនៅក្នុងតុលាការ ចៅក្រមជំនុំជម្រះ តែងតែណែនាំភាគីវិវាទឲ្យព្យាយាមប្រើប្រាស់សន្ទានកម្ម មុនពេលដំណើរការនីតិវិធីបន្តទៀត[19]។ ដំណើរការនៃនីតិវិធីអាចត្រូវបានបញ្ឈប់នៅពេលណាដែលភាគីវិវាទសម្រេចចិត្តដោះស្រាយបញ្ហាតាមរយៈការប្រើប្រាស់សន្ទានកម្មនេះ ដោយក្នុងនោះភាគីវិវាទ អាចប្រើប្រាស់ការសន្ទានការីរបស់តុលាការ (តែងតាំងដោយតុលាការ) ឬសន្ទានការីក្រៅតុលាការ[19]។

ជំនួសឲ្យការទៅតុលាការ ភាគីវិវាទ អាចស្វែងរកសេវាសន្ទានកម្មក្រៅប្រព័ន្ធតុលាការនៅ មជ្ឈមណ្ឌលសន្ទានកម្ម ដែលស្ថិតនៅក្រោមមជ្ឈមណ្ឌលដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ (Mediation Center in the Alternative Dispute Resolution Center) ការិយាល័យតុលាការ (Office of the Judiciary) ក្រសួងយុត្តិធម៌ មជ្ឈមណ្ឌលសន្ទានកម្ម THAC (THAC Mediation Center) និងក្រុមប្រឹក្សាមេធាវីនៃប្រទេសថៃ (Lawyer Council of Thailand)[19]។ សន្ទានការី ជួយស្វែងរកដំណោះស្រាយសមរម្យសម្រាប់ភាគីទាំងពីរ។ បន្ទាប់មក ភាគីវិវាទ អាចចរចាគ្នា ដោយផ្អែកលើដំណោះស្រាយផ្តល់ដោយសន្ទានការីដែលនាំឲ្យភាគីវិវាទឈានដល់កិច្ចព្រមព្រៀងមួយ នៅចុងបញ្ចប់នៃដំណើរការសន្ទានកម្មនេះ។ ប្រសិនបើមិនសម្រេចបាននូវកិច្ចព្រមព្រៀងទេនោះ ភាគីណាមួយ អាចប្តឹងទៅដល់តុលាការ[17]។

### ៤ .២. មជ្ឈត្តកម្ម

ផ្ទុយពីសន្ទានកម្ម មជ្ឈត្តកម្ម ត្រូវបានប្រើប្រាស់នៅក្នុងវិវាទពាណិជ្ជកម្មធ្ងន់ធ្ងរ និងមានតម្លៃខ្ពស់។ លើសពីនេះទៀត ភាគីវិវាទ ត្រូវចំណាយថវិកាយ៉ាងច្រើនទៅលើទាំងមជ្ឈត្តករ និងស្ថាប័នដែលផ្តល់សេវាមជ្ឈត្តកម្មនេះ។ រាជរដ្ឋាភិបាលថៃ បានបង្កើតច្បាប់គំរូ UNCITRAL ស្តីពីមជ្ឈត្តករក្នុងពាណិជ្ជកម្មអន្តរជាតិ (UNCITRAL Model Law on International Commercial Arbitration) សម្រាប់ជាយន្តការដាក់លាក់ដើម្បីអនុវត្តក្របខ័ណ្ឌមជ្ឈត្តកម្មអន្តរជាតិចំពោះវិវាទកើតមានក្នុងប្រទេសថៃ។ នៅក្នុងដំណើរការមជ្ឈត្តកម្ម ភាគីវិវាទ អាចរៀបចំនីតិវិធីចរចាដោយខ្លួនឯង ដើម្បីធានាថា សំណើរបស់ភាគីនីមួយៗអាចត្រូវបានទទួលដឹងលឺដោយភាគីម្ខាងទៀត[17]។

តុលាការ ជាតួអង្គដ៏សំខាន់ក្នុងការដាក់ឲ្យអនុវត្តនូវកិច្ចព្រមព្រៀង ដែលកើតចេញពីដំណើរការមជ្ឈត្តកម្ម ទាំងមជ្ឈត្តកម្មនៅក្នុងតុលាការ និងមជ្ឈត្តកម្មក្រៅតុលាការ។ ប្រសិនបើភាគីណាមួយ មិនយល់ព្រមចំពោះ បញ្ញត្តិណាមួយនៅក្នុងកិច្ចព្រមព្រៀងនោះ តុលាការ មានសិទ្ធិអំណាចចាត់តាំងមជ្ឈត្តករ ដើម្បីជួយសម្រួល និងរកដំណោះស្រាយសមរម្យសម្រាប់ភាគីទាំងពីរ[17]។

ក្រៅពីការប្រើប្រាស់មជ្ឈត្តកម្មនៅក្នុងវិវាទពាណិជ្ជកម្ម ភ្នាក់ងាររាជរដ្ឋាភិបាលជាច្រើន ដូចជានាយកដ្ឋាន ធានារ៉ាប់រង (Department of Insurance) នាយកដ្ឋានកម្មសិទ្ធិបញ្ញា (Department of Intellectual Property) និងគណៈកម្មការទីផ្សារមូលបត្រ (Security and Exchange Commission) ក៏បានប្រើប្រាស់ ដំណើរការមជ្ឈត្តកម្មនេះផងដែរ[17]។

សេវាមជ្ឈត្តកម្មក្រៅតុលាការ អាចរកបាននៅវិទ្យាស្ថានមជ្ឈត្តកម្មនៃប្រទេសថៃ (Thai Arbitration Institute) មជ្ឈមណ្ឌលមជ្ឈត្តកម្ម THAC (THAC Arbitration Center) ការិយាល័យនៃគណៈកម្មការ ធានារ៉ាប់រង (Office of Insurance Commission) ទីផ្សារភាគហ៊ុនថៃ(Stock Exchange of Thailand) និងសភាពាណិជ្ជកម្មអន្តរជាតិ (International Chamber of Commerce)។ មជ្ឈត្តកម្មក្រៅតុលាការ ស្ថិត នៅក្រោមច្បាប់ស្ដីពីមជ្ឈត្តកម្មឆ្នាំ២០០២ (2002 Arbitration Act)។ រយៈពេលជាមធ្យមសម្រាប់ដំណើរ ការមជ្ឈត្តកម្មក្រៅតុលាការ គឺប្រហែលមួយឆ្នាំ ឯតម្លៃ គឺអាស្រ័យទៅលើទីតាំង និងនីតិវិធីដែលយកមកប្រើ ប្រាស់។ ឧទាហរណ៍ ការចំណាយទៅលើការដោះស្រាយវិវាទ ដោយប្រើប្រាស់សេវាមជ្ឈត្តកម្មនៅវិទ្យាស្ថាន មជ្ឈត្តកម្មនៃប្រទេសថៃ (Thai Arbitration Institute) អាចមិនលើសពី ២លានបាត (ប្រហែល៦០,០០០ ដុល្លារអាមេរិក) ដែលក្នុងនោះមានតម្លៃឈ្នួលមជ្ឈត្តករ ប្រហែល៣០,០០០បាត (ប្រហែល៩០០ដុល្លារអា មេរិក)[17] ហើយថ្លៃឈ្នួលដែលនៅនឹងត្រូវជាកម្មសិទ្ធរបស់ស្ថាប័នមជ្ឈត្តកម្ម ។

មជ្ឈត្តកម្មក្រៅតុលាការមានពីរប្រភេទ គឺមជ្ឈត្តកម្មអាដហុក (ad hoc arbitration) និងមជ្ឈត្តកម្មស្ថាប័ន (institutional arbitration)។ មជ្ឈត្តកម្មអាដហុក (ad hoc arbitration) មិនចំណាយច្រើនទេ ដោយសារភាគីវិវាទ គ្រប់គ្រងដំណើរការនីតិវិធីទាំងអស់ដោយខ្លួនឯង និងអាចពិភាក្សាតម្លៃជាមួយមជ្ឈត្តករ បានគ្រប់ពេល។ ក្នុងករណីនៃមជ្ឈត្តកម្មស្ថាប័ន (institutional arbitration) ភាគីវិវាទ ត្រូវចំណាយថវិកា យ៉ាងច្រើន ដោយសារតែពួកគេ ត្រូវគោរពតាមបទបញ្ជា និងនីតិវិធីរបស់ស្ថាប័នដែលពួកគេប្រើប្រាស់[17] ។

## ៥. សេចក្ដីសន្និដ្ឋាន

ប្រទេសថៃ មានកំណែទម្រង់សំខាន់ទៅលើប្រព័ន្ធតុលាការ នៅពេលដែលរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៧ កំពុងត្រូវ បានអនុវត្ត។ កំណែទម្រង់នេះ បានផ្ដាច់តុលាការពីក្រសួងយុត្តិធម៌ អនុលោមទៅតាមគោលគំនិតគន្លឹះនៃឯក រាជ្យភាពនៃប្រព័ន្ធតុលាការ ជាពិសេសឯករាជ្យភាពពីអំណាចនីតិប្រតិបត្តិ។ លើសពីនេះ គណៈកម្មការ តុលាការ (Judicial Commission) ដើរតួនាទីយ៉ាងសំខាន់ក្នុងការត្រួតពិនិត្យទៅលើរដ្ឋបាលរបស់តុលាការ យុត្តិធម៌ និងធានាទៅលើការអនុវត្តបទបញ្ញាផ្ទៃក្នុង ពាក់ព័ន្ធនឹងការតែងតាំង ការតម្លើងឋានៈ និងការដាក់ ទណ្ឌកម្មវិន័យទៅលើចៅក្រម។ ឯករាជ្យភាពស្ថាប័ន និងឯករាជ្យភាពរបស់ចៅក្រម ត្រូវបានធានាដោយរដ្ឋ

ធម្មនុញ្ញ និងច្បាប់។ ក្រៅពីការដោះស្រាយវិវាទក្នុងប្រព័ន្ធតុលាការ ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ (ADR) គឺជាមធ្យោបាយមួយ ដែលអនុវត្តនៅក្នុងប្រទេសថៃ ដើម្បីដោះស្រាយវិវាទស៊ីវិល គ្រួសារ ជំនួញ និង ពាណិជ្ជកម្ម។ ADR ផ្អែកទៅលើកិច្ចព្រមព្រៀង ហើយប្រសិនបើភាគីទាំងពីរ មិនសប្បាយចិត្តនឹងការសម្រេច ចុងក្រោយ ភាគីវិវាទអាចទៅតុលាការដែលជាជម្រើសចុងក្រោយ។

# ឧបសម្ព័ន្ធ ១

## ១. រដ្ឋសភាប្រទេសថៃ

យោងតាមមាត្រា៧៩ នៃរដ្ឋធម្មនុញ្ញឆ្នាំ២០១៧ ប្រទេសថៃ មានសភាចំនួនពីរគឺ សភាតំណាងរាស្ត្រ(សភាជាន់ទាប) និងព្រឹទ្ធសភា(សភាជាន់ខ្ពស់)។ ម្យ៉ាងវិញទៀត ផ្នែកទី៨៣ នៃរដ្ឋធម្មនុញ្ញឆ្នាំ២០១៧ ចំនួនសមាជិកសភាតំណាងរាស្ត្រមានចំនួន៥០០នាក់ ដែលត្រូវបានជ្រើសរើសតាមរយៈការបោះឆ្នោតនៅតាមមណ្ឌលនីមួយៗ និងតាមរយៈបញ្ជីឈ្មោះបេក្ខជននៃគណបក្សនយោបាយ។ រដ្ឋធម្មនុញ្ញតម្រូវឱ្យសភាតំណាងរាស្ត្រមានសមាជិកចំនួនប្រាំរយនាក់ ត្រូវបានបោះឆ្នោតជ្រើសរើសតាមរយៈការបោះឆ្នោតជាសកល (១) សមាជិកចំនួន៣៥០នាក់ ត្រូវបានបោះឆ្នោតជ្រើសរើសតាមរយៈការឈរឈ្មោះដោយផ្ទាល់នៅតាមមណ្ឌលបោះឆ្នោត (២) សមាជិកចំនួន១៥០នាក់ គឺ បេក្ខភាពដែលឈរឈ្មោះមកពីគណបក្សដែលត្រូវបោះឆ្នោតដោយប្រយោលតាមរយៈភាគរយនៃសម្លេងឆ្នោត។ យោងតាមផ្នែកទី១០៧ នៃរដ្ឋធម្មនុញ្ញឆ្នាំ២០១៧ សមាជិកព្រឹទ្ធសភាមានចំនួន២០០នាក់ ត្រូវបានជ្រើសរើសចេញពីបុគ្គលដែលមានចំណេះដឹងជំនាញ និងបទពិសោធន៍ការងារ តាមរយៈព្រះរាជក្រឹត្យ។

នៅខែឧសភាឆ្នាំ២០១៤ មានរដ្ឋប្រហារយោធាមួយនៅក្នុងប្រទេសថៃ។ ពួកយោធាបានរំលាយសភាហើយបានបង្កើតរដ្ឋសភានីតិប្បញ្ញត្តិជាតិ (NLA) ដែលស្ថិតនៅក្រោមរដ្ឋធម្មនុញ្ញឆ្នាំ២០១៤ ដើម្បីជំនួសឲ្យរដ្ឋសភានៃប្រទេសថៃ(NAT)ដែលរួមមាន សភាតំណាងរាស្ត្រ និងព្រឹទ្ធសភា[b]។ រដ្ឋសភានីតិប្បញ្ញត្តិជាតិ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រុមប្រឹក្សាជាតិសន្តិភាព និងសណ្ដាប់ធ្នាប់។ រហូតមកដល់ឆ្នាំ២០១៧ គណៈកម្មាធិការពង្រាងរដ្ឋធម្មនុញ្ញ បានបង្កើតឲ្យមានរដ្ឋធម្មនុញ្ញបណ្ដោះអាសន្នឆ្នាំ២០១៧ ។ តាមរយៈរដ្ឋធម្មនុញ្ញនេះ រដ្ឋសភានៃប្រទេសថៃ នឹងត្រូវបានបង្កើតឡើងវិញនៅពេលមានការបោះឆ្នោតជាតិនាពេលខាងមុខនេះ។ ដូច្នេះ រដ្ឋសភានីតិប្បញ្ញត្តិជាតិ នៅតែដំណើរការនៅក្នុងប្រទេសថៃ[c]។

## ២. ដំណើរការធ្វើច្បាប់របស់ប្រទេសថៃ

ដោយសារតែពុំមានព្រឹទ្ធសភា និងរដ្ឋសភាជាតិ សភានីតិប្បញ្ញត្តិជាតិ បានដើរតួនាទីជាសភានៃប្រទេសថៃ ដូចនេះ ដំណើរការធ្វើច្បាប់ខាងក្រោមនេះ គឺផ្អែកលើរដ្ឋធម្មនុញ្ញឆ្នាំ២០០៧ និងរដ្ឋធម្មនុញ្ញបណ្ដោះអាសន្នឆ្នាំ២០១៧។

យោងតាមផ្នែកទី១៤២ នៃរដ្ឋធម្មនុញ្ញឆ្នាំ២០០៧ បុគ្គល ឬភ្នាក់ងារណាដែលអាចធ្វើសេចក្តីស្នើច្បាប់ ឬធ្វើសេចក្តីព្រាងច្បាប់រួមមាន៖(១)ទីស្តីការគណៈរដ្ឋមន្ត្រី (២)សមាជិកសភាតំណាងរាស្ត្រច្រើនជាង២០រូប (៣)តុលាការ ឬទីភ្នាក់ងារច្បាប់ និង(៤)ប្រជាពលរដ្ឋច្រើនជាង១០.០០០នាក់ ដែលមានសិទ្ធិបោះឆ្នោត។ ក្នុងករណីដែលសេចក្តីស្នើច្បាប់ ឬសេចក្តីព្រាងច្បាប់ ពាក់ព័ន្ធនឹងហិរញ្ញវត្ថុ ដែលស្នើមកពីសមាជិកសភា

---

[b] National Legislative Assembly. 2017. *History of the National Legislative Assembly.* http://w3c.senate.go.th/main.php?url=content&id=513 [Access on 23 August 2017].
[c] *National Council for Peace and Order*. 2017.

តំណាងរាស្ត្រ តុលាការ និងប្រជាពលរដ្ឋ នាយករដ្ឋមន្ត្រីត្រូវធ្វើការសម្រេចចិត្តថាតើត្រូវគាំទ្រ ឬបដិសេធ។ នៅក្នុងផ្នែកនេះក៏បានបញ្ជាក់ផងដែរថា គ្រប់ច្បាប់ទាំងអស់ត្រូវតែពិនិត្យដោយសភាតំណាងរាស្ត្រជាមុន។ ច្បាប់ដែលត្រូវចាត់ទុកជាច្បាប់ហិរញ្ញវត្ថុ ត្រូវមានលក្ខណៈមួយ ក្នុងចំណោមលក្ខណៈទាំងនេះ៖(១)ពន្ធ (២) ថវិការដ្ឋ (៣)ទ្រព្យសកម្មរបស់រដ្ឋ និង(៤)រូបិយប័ណ្ណ។ ប្រសិនបើមានការសង្ស័យថាច្បាប់ណាមួយ ជាច្បាប់ហិរញ្ញវត្ថុ ឬអត់ ដែលតម្រូវឱ្យមានការសម្រេចពីនាយករដ្ឋមន្ត្រី ប្រធានសភាតំណាងរាស្ត្រ និងប្រធានគណៈកម្មាធិការអេចិន្ត្រៃយ៍ ត្រូវរួមគ្នាសម្រេចនៅក្នុងកិច្ចប្រជុំ ថាតើច្បាប់នោះជាច្បាប់ហិរញ្ញវត្ថុ ឬទេ ក្នុងរយៈពេល១៥ថ្ងៃ តាមរយៈការបោះឆ្នោតមតិភាគច្រើន។ ក្នុងករណីការបោះឆ្នោតមានចំនួនស្មើគ្នា ប្រធានសភាតំណាងរាស្ត្រក៏ត្រូវបោះឆ្នោតផងដែរ(ផ្នែកទី១៤៣ នៃរដ្ឋធម្មនុញ្ញ)។

យោងតាមផ្នែកទី១៤៦ នៃរដ្ឋធម្មនុញ្ញឆ្នាំ២០០៧ បន្ទាប់ពីសភាតំណាងរាស្ត្របោះឆ្នោតគាំទ្រសេចក្តីស្នើ ឬសេចក្តីព្រាងច្បាប់ ច្បាប់នេះត្រូវដាក់ជូនទៅព្រឹទ្ធសភា។ ព្រឹទ្ធសភាត្រូវពិនិត្យមើលក្នុងរយៈពេល៦០ថ្ងៃ និងក្នុងរយៈពេល៣០ថ្ងៃ ចំពោះច្បាប់ស្តីពីហិរញ្ញវត្ថុ។ ទោះជាយ៉ាងណាក៏ដោយ ក្នុងករណីខ្លះ ព្រឹទ្ធសភាអាចពន្យារពេល តែមិនឲ្យលើសពី៣០ថ្ងៃ។ ច្បាប់នេះត្រូវចាត់ទុកថា បានអនុម័តដោយព្រឹទ្ធសភា ក្នុងករណីព្រឹទ្ធសភាខកខានធ្វើសេចក្តីសម្រេចក្នុងរយៈពេលដែលបានកំណត់។

យោងតាមផ្នែកទី១៤៧ និងផ្នែកទី១៥០ រដ្ឋធម្មនុញ្ញឆ្នាំ២០០៧ ដំណាក់កាលបន្ទាប់ក្នុងដំណើរការធ្វើច្បាប់មានដូចខាងក្រោម៖

១. ប្រសិនបើព្រឹទ្ធសភាអនុម័ត សេចក្តីស្នើច្បាប់ ឬសេចក្តីព្រាងច្បាប់នោះ ត្រូវបញ្ជូនទៅសភាតំណាងរាស្ត្រ បន្ទាប់មកបញ្ជូនទៅនាយករដ្ឋមន្ត្រី។ ក្នុងរយៈពេល២០ថ្ងៃ នាយករដ្ឋមន្ត្រីស្នើសុំព្រះមហាក្សត្រឡាយព្រះហស្តលេខា។ បន្ទាប់ពីព្រះមហាក្សត្រឡាយព្រះហស្តលេខារួច ច្បាប់នោះត្រូវបោះពុម្ពផ្សាយនៅលើកាសែតរាជរដ្ឋាភិបាលដើម្បីចូលជាធរមាន។

២. ក្នុងករណីព្រឹទ្ធសភាធ្វើវិសោធនកម្មលើច្បាប់ និងមានការគាំទ្រពីសភាតំណាងរាស្ត្រ ដំណើការធ្វើច្បាប់អនុវត្តដូចគ្នានឹងចំនុចទី១ខាងលើ ។

៣.ប្រសិនបើព្រឹទ្ធសភាមិនគាំទ្រលើសេចក្តីស្នើច្បាប់ ឬសេចក្តីព្រាងច្បាប់នោះទេ សេចក្តីស្នើច្បាប់ ឬសេចក្តីព្រាងច្បាប់នោះ នឹងត្រូវបញ្ជូនទៅសភាតំណាងរាស្ត្រដើម្បីធ្វើការពិចារណាសារជាថ្មី។

៤. ក្នុងករណីចំនុចទី៣ខាងលើ ប្រសិនបើសភាតំណាងរាស្ត្រមិនគាំទ្រការធ្វើវិសោធនកម្មរបស់ព្រឹទ្ធសភា គណៈកម្មាធិការរួម (Joint Committee) ត្រូវបានបង្កើតឡើង ដោយមានសមាជិកមកពីសភាទាំងពីរ និងមានចំនួនស្មើគ្នា ដែលកំណត់ដោយសភាតំណាងរាស្ត្រ។ គណៈកម្មាធិការរួមនេះនឹងពិនិត្យឡើងវិញនូវច្បាប់នោះ ធ្វើរបាយការណ៍ នឹងដាក់ជូនទៅសភាតំណាងរាស្ត្រ និងព្រឹទ្ធសភា។ គណៈកម្មាធិការរួម មានអំណាចក្នុងការកោះហៅអ្នកពាក់ព័ន្ធ ដើម្បីទទួលបានពត៌មានបន្ថែម (ទិន្នន័យ និងភស្តុតាង) ទាក់ទងនឹងច្បាប់នោះ។ ប្រសិនបើ សេចក្តីស្នើច្បាប់ ឬសេចក្តីព្រាងច្បាប់នោះត្រូវបានគាំទ្រដោយសភាទាំងពីរ ដំណើរការធ្វើច្បាប់ដូចគ្នានឹងចំនុចទី១ដែរ។ ប្រសិនបើ

ព្រឹទ្ធសភា និងសភាតំណាងរាស្ត្រមិនគាំទ្រ សេចក្តីស្នើច្បាប់ ឬសេចក្តីព្រាងច្បាប់នោះ នឹងត្រូវបានបដិសេធ។

៥. យោងតាមផ្នែកទី១៤៨ សេចក្តីស្នើច្បាប់ ឬសេចក្តីព្រាងច្បាប់ដែលត្រូវបានបដិសេធនោះ នឹងត្រូវពិចារណាឡើងវិញបន្ទាប់ពីរយៈពេល១៨០ថ្ងៃ។ ក្នុងករណីដែលសភាតំណាងរាស្ត្រ នៅតែគាំទ្រលើច្បាប់ដដែលនោះ ឬមានការគាំទ្រដោយចំនួនភាគច្រើននៃគណៈកម្មាធិការរួម ដំណើរការធ្វើច្បាប់នោះដូចគ្នានឹងចំនុចទី១។

៦.យោងតាមផ្នែកទី១៤១ នៃរដ្ឋធម្មនុញ្ញឆ្នាំ២០០៧ មុនពេលច្បាប់អង្គការ ត្រូវបញ្ជូនទៅព្រះមហាក្សត្រដើម្បីឡាយព្រះហស្តលេខា នាយករដ្ឋមន្ត្រីត្រូវផ្ញើច្បាប់ចម្លង ទៅតុលាការធម្មនុញ្ញ ដើម្បីធានាថាច្បាប់នោះស្របនឹងរដ្ឋធម្មនុញ្ញ។

មានភាពខុសគ្នាតិចតួចរវាងរដ្ឋធម្មនុញ្ញឆ្នាំ២០០៧ និងរដ្ឋធម្មនុញ្ញបណ្តោះអាសន្នឆ្នាំ២០១៧ (សូមមើលរូបភាពទី១ខាងក្រោម)។ ភាពខុសគ្នានេះទាក់ទងនឹងបុគ្គលដែលអាចស្នើ ឬធ្វើសេចក្តីព្រាងច្បាប់។ យោងតាមផ្នែកទី១៣៣ រដ្ឋធម្មនុញ្ញឆ្នាំ២០១៧ គណៈរដ្ឋមន្ត្រី សមាជិកសភាតំណាងរាស្ត្រច្រើនជាង២០រូប និងប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតលើសពី១០.០០០នាក់ អាចធ្វើសេចក្តីស្នើច្បាប់បាន។ ចំពោះច្បាប់អង្គការ មានតែគណៈរដ្ឋមន្ត្រី[d] និងសមាជិកសភាតំណាងរាស្ត្រទេដែលអាចធ្វើសេចក្តីស្នើច្បាប់ ទៅរដ្ឋសភាជាតិ។ បើប្រៀបធៀបទៅនឹងរដ្ឋធម្មនុញ្ញឆ្នាំ២០០៧ តុលាការ ឬភ្នាក់ងារច្បាប់ក៏អាចធ្វើសេចក្តីស្នើច្បាប់ទាក់ទងនឹងភារកិច្ច និងតួនាទីរបស់ខ្លួន។ ក្រៅពីភាពខុសគ្នានេះដំណើរការធ្វើច្បាប់ទាំងអស់ គឺនៅដដែលរវាងរដ្ឋធម្មនុញ្ញឆ្នាំ២០០៧ និងរដ្ឋធម្មនុញ្ញឆ្នាំ២០១៧ ។

[d] គណៈរដ្ឋមន្ត្រី ធ្វើសេចក្តីស្នើច្បាប់អង្គការ ដោយមានការផ្តល់យោបល់ពីតុលាការកំពូល ឬតុលាការធម្មនុញ្ញ។

**តារាងទី ១៖ ដំណើរការធ្វើច្បាប់របស់ប្រទេសថៃ**




[e] មានចែងនៅក្នុងផ្នែកទី១៤២ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រថៃ ឆ្នាំ២០០៧។

# ឧបសម្ព័ន្ធ ២

បន្ទាប់ពីបទបង្ហាញដែលបានប្រព្រឹត្តទៅនៅថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៧ សម្រាប់គណៈកម្មការទី៦ នៃព្រឹទ្ធសភា គណៈកម្មការ មានសំណួរចំនួន៤ដូចខាងក្រោម។ ឧបសម្ព័ន្ធ២នេះ ផ្តល់ចម្លើយចំពោះសំណួរទាំងអស់នេះ។

## សំណួរ

១ .តើព្រះមហាក្សត្រនៃព្រះរាជាណាចក្រថៃ មានអំណាចលើកលែងទោសដល់អ្នកទោសឬទេ?

២. ក្នុងករណីប្រធានតុលាការកំពូល មានកំហុស តើនរណា ជាអ្នកដាក់ទណ្ឌកម្ម?

៣ .តើរដ្ឋធម្មនុញ្ញឆ្នាំ២០០៧ និងរដ្ឋធម្មនុញ្ញបណ្តោះអាសន្នឆ្នាំ២០១៧ មានលក្ខណៈខុសគ្នាយ៉ាងដូចម្តេចខ្លះ?

៤. តើតុលាការយុត្តិធម៌នៅក្នុងប្រទេសថៃ ត្រូវបានបែងចែកជាប៉ុន្មានផ្នែក?

## ចម្លើយ

១ .យោងតាមមាត្រា២ នៃរដ្ឋធម្មនុញ្ញបណ្តោះអាសន្នឆ្នាំ២០១៧ ព្រះមហាក្សត្រ ជាប្រមុខរដ្ឋ។ មាត្រា៨ បានបញ្ជាក់ថា ព្រះមហាក្សត្រ ក៏ជាអគ្គបញ្ជាការកងកម្លាំងប្រដាប់អាវុធរបស់ប្រទេសថៃ។ បន្ថែមពីនេះទៀត យោងតាមមាត្រា១៧៩ ព្រះមហាក្សត្រ មានអំណាចលើកលែងទោស។ ដោយសារប្រទេសថៃ ជាប្រទេសប្រកាន់រាជាធិបតេយ្យអាស្រ័យរដ្ឋធម្មនុញ្ញ អំណាចរបស់ព្រះមហាក្សត្រ មានកម្រិត។ ទោះជាយ៉ាងណាក៏ដោយ ព្រះមហាក្សត្រ នៅតែមានអំណាចលើកលែងទោសដល់អ្នកទោស។ ឧទាហរណ៍ នៅក្នុងឆ្នាំ២០១៦ ព្រះមហាក្សត្រ បានប្រកាសលើកលែងទោសដល់អ្នកទោសចំនួន១៥០,០០០នាក់ និងបន្ធូរបន្ថយរយៈពេលជាប់ពន្ធនាគាររបស់អ្នកទោសរាប់ពាន់នាក់។ ការលើកលែងទោស មានពីរប្រភេទ ដូចខាងក្រោម៖

ក. **ការលើកលែងទោសជារួម៖** ការលើកលែងទោសជារួម ត្រូវបានធ្វើឡើងនៅពេលមានព្រឹត្តិការណ៍ជាតិពិសេសៗ ដូចជាព្រះរាជពិធីចម្រើនព្រះជន្មរបស់ព្រះមហាក្សត្រ និងព្រះមហាក្សត្រី។ ដំណើរការនៃការលើកលែងទោសជារួម ត្រូវបានស្នើទៅកាន់ព្រះមហាក្សត្រដោយគណៈរដ្ឋមន្ត្រី ដើម្បីប្រកាសជាផ្លូវការសូមមើលរូប)ភាពទី១ខាងក្រោមចាប់ពីចំណុចគណៈរដ្ឋមន្ត្រី(។

ខ .**ការលើកលែងទោសជាឯកត្តបុគ្គល៖** អ្នកទោស ឬជនដែលពាក់ព័ន្ធ ឪពុកម្តាយ)កូនរបស់អ្នកទោសនិងប្រពន្ធ ឬប្តី(។ ដំណើរការនៃការស្នើលើកលែងទោសពីព្រះមហាក្សត្រ មានដូចរូបភាពខាងក្រោម។

២. យោងតាមជំពូកទី៥ ស្តីពី» វិន័យ ការរក្សាវិន័យ ទណ្ឌកម្ម និងភាពខុសប្រក្រតី «នៃច្បាប់ស្តីពីសេវាយុត្តិធម៌របស់តុលាការយុត្តិធម៌ មិនមានមាត្រាដាក់លាក់ណាមួយបញ្ជាក់ពីការដាក់ទណ្ឌកម្មទៅលើប្រធានតុលាការកំពូល) ប្រធានគណៈកម្មការតុលាការ( ប្រសិនបើប្រធានតុលាការកំពូល បានធ្វើកំហុសឆ្គងណាមួយឡើយ។ នៅក្នុងច្បាប់ស្តីពីសេវាយុត្តិធម៌របស់តុលាការយុត្តិធម៌ បានចែងពីការដាក់ទណ្ឌកម្មទូទៅ ទៅលើចៅក្រម ដោយការដាក់ទណ្ឌកម្មនេះ ដឹកនាំដោយប្រធានគណៈកម្មការតុលាការ និងតាមរយៈការស៊ើបអង្កេត។

៣. រដ្ឋធម្មនុញ្ញបណ្តោះអាសន្នឆ្នាំ២០១៧ មិនខុសគ្នាពីរដ្ឋធម្មនុញ្ញឆ្នាំ២០០៧ឡើយ។ រដ្ឋធម្មនុញ្ញឆ្នាំ២០១៧ គ្រាន់តែជាវិសោធនកម្មនៃរដ្ឋធម្មនុញ្ញឆ្នាំ២០០៧ ដែលផ្នែកខ្លះនៃរដ្ឋធម្មនុញ្ញ ត្រូវបានដាក់បញ្ចូលគ្នា។ នៅក្នុងរដ្ឋធម្មនុញ្ញឆ្នាំ២០០៧ សមាជិកសភាតំណាងរាស្រ្ត មានចំនួន៤៨០រូប ចំណែករដ្ឋធម្មនុញ្ញឆ្នាំ២០១៧ សមាជិក មានចំនួន៥០០រូប។ ព្រឹទ្ធសភា មានសមាជិកចំនួន១៥០រូប ដោយធ្វើឡើងតាមរយៈការបោះឆ្នោតពីខេត្តនីមួយៗ រដ្ឋធម្មនុញ្ញឆ្នាំ)២០០៧) ឯរដ្ឋធម្មនុញ្ញឆ្នាំ២០១៧ សមាជិកព្រឹទ្ធសភា ត្រូវបានជ្រើសរើសពីបុគ្គល ដែលមានចំណេះដឹង វិជ្ជាជីវៈ និងបទពិសោធន៍។ យោងតាមមាត្រា ១០៧ នៃរដ្ឋធម្មនុញ្ញឆ្នាំ២០១៧ បានចែងថា »ការជ្រើសរើសសមាជិកព្រឹទ្ធសភា ត្រូវធ្វើតាមព្រះរាជក្រឹត្យនិងក្នុងរយៈពេល៥ថ្ងៃចាប់ពីថ្ងៃដែលព្រះរាជក្រឹត្យ ចូលជាធរ គណៈកម្មការបោះឆ្នោត[f] ត្រូវកំណត់កាលបរិច្ឆេទនៃការចាប់ផ្តើមការជ្រើសរើស និងមិនលើសពី៣០ថ្ងៃ ចាប់ពីថ្ងៃដែលព្រះរាជក្រឹត្យ ចូលជាធរមាន»។ លក្ខណៈខុសគ្នាសំខាន់នោះ គឺជំពូកទី១៦ ស្តីពីកំណែទម្រង់ជាតិ ដែលផ្តោតទៅលើសន្តិភាព និងសណ្តាប់ធ្នាប់របស់ប្រទេសជាតិ។

៤. តុលាការនៃព្រះរាជាណាចក្រថៃ មាន៣កម្រិត ដែលត្រូវបានគេស្គាល់ជាទូទៅថាជាតុលាការយុត្តិធម៌។ តុលាការកំពូល គឺជាតុលាការ ដែលមានកម្រិតខ្ពស់បំផុត ឯកម្រិតបន្ទាប់ គឺសាលាឧទ្ធរណ៍ និងកម្រិតទាបបំផុត គឺសាលាដំបូង។ សាលាដំបូង ត្រូវបានបែងចែកជា តុលាការទូទៅ[g] តុលាការអនីតិជន និងគ្រួសារ និងតុលាការពិសេស។

[f] គណៈកម្មការបោះឆ្នោត មានសមាជិក៧រូប ដែលតែងតាំងដោយព្រះមហាក្សត្រ តាមមតិយោបល់របស់ព្រឹទ្ធសភា។

[g] តុលាការទូទៅ មានអំណាចជំនុំជម្រះរឿងក្តីព្រហ្មទណ្ឌ និងរដ្ឋប្បវេណី

រូបភាពទី ១ដំណើរការនៃការដាក់ញត្តិ :លើកលែងទោសជាឯកត្តជន[h]




[h] Thai Prison Life .(2017). *Royal Pardon*,Thailand. Available http://www.thaiprisonlife.com/royal-pardon/ [Accessed 12 September.2017]

# ឯកសារយោង


1. WORLD BANK. Judicial Independence: What It Is, How It Can Be Measured, Why It Occures. Available: http://siteresources.worldbank.org/INTLAWJUSTINST/Resources/JudicialIndependence.pdf [Accessed 15 August 2017].
2. THE NATIONAL LEGISLATIVE ASSEMBLY. (2017). *History of the National Legislative Assembley* [Online]. Thailand. Available: http://w3c.senate.go.th/main.php?url=content&id=513 [Accessed 7 August 2017].
3. INTERNATIONAL INSTITUTE FOR DEMOCRACY AND ELECTORAL ASSISTANCE, UNITED NATIONS RESIDENT COORDINATOR IN THAILAND & INTERNATIONAL COMMISSION OF JUSRISTS (2016). Consitution of Thailand United Nations
4. NGAMNET, T., SANSANEE, P. & SIRIKANANG, C. (2004). Overview of Legal Systems in the Asia-Pasific Region: Thailand. Harriet Stein Mancuso Amphitheater Cornell Law School
5. COURT OF JUSTICE. (2017). *Judicial System* [Online]. Thailand. Available: http://www.coj.go.th/en/judicialsystem.html
6. THE ADMINSTRATIVE COURT OF THAILAND. (2017). *Brief Overview* [Online]. Thailand. Available: http://www.admincourt.go.th/admincourt/site/?lang=en&page=03brief [Accessed 10 August 2017].
7. THE CONSTITUTIONAL COURT OF KINGDOM OF THAILAND (2017). Power and Duties of Constitutional Court The Constitutional Court of Thailand.
8. JUSTICE, C. O. (2017). *Structure of the Courts of Justice* [Online]. Thailand. Available: http://www.coj.go.th/en/cojstructure.html [Accessed 16 August 2017].
9. LINDA CAMP, K. (2002). Judicial Independence and Human Rights Protection Around the World. *Judicature* 85.
10. UNITED NATIONS HUMAN RIGHTS. (2017). *Basic Principles on the Independence of the Judiciary* [Online]. Available: http://www.ohchr.org/EN/ProfessionalInterest/Pages/IndependenceJudiciary.aspx [Accessed 23 August 2017].
11. (2000). Act on the Judicial Service of the Courts of Justice. Thailand: Royal Gazette
12. COMMISSION FOR JUDICIAL SERVICE (2000). Act on Judicial Administration of the Court of Justice. Thailand.
13. TEJ BAHADUR, S. (1996). Principle of Separation of Powers and Concentration of Authority.
14. UNITED NATIONS ECONOMIC AND SOCIAL COUNCIL (2006). Strengthening Basic Principle of Judicial Conduct United Nation
15. DAVID, P. (2016). Balancing Judicial Independence and Accountability in a Transitional State: The Case of Thailand. Available: http://escholarship.org/uc/item/6gr416nk#page-1.
16. WORLD BANK. (2017). *Judicial Independence* [Online]. World Bank. Available: http://tcdata360.worldbank.org/indicators/jud.ndep?country=THA&indicator=669&countries=KHM&viz=line_chart&years=2007,2016 [Accessed 23 August 2017].
17. SIAM LEGAL. (2017). *Arbitration* [Online]. Thailand. Available: http://www.siam-legal.com/litigation/arbitration-in-thailand.php [Accessed 10 August 2017].
18. THE ADMINSTRATIVE COURT OF THAILAND (2016). Alternative Dispute Resolution in Administrative Matters. Istanbul Turkey: the Administrative Court.
19. DEJ-UDOM ASSOCITES. (2017). *Arbitration and Mediation in Thailand* [Online]. Thailand. Available: https://www.aihja.org/images/users/114/files/Thailand_-_Report_2016_Thailand_-_Report_2016.pdf [Accessed 10 August 2017].